# ស្ថានភាពអតិផរណានៅខែវិច្ឆិកា ឆ្នាំ២០១៧

## ក/ អតិផរណាក្នុងប្រទេស

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ បានកើនឡើងក្នុងអត្រា **0,២%** ធៀបនឹងខែមុន និងកើនឡើង **២,៣%** បើធៀបនឹង១២ខែមុន។

សន្ទស្សន៍ថ្លៃក្រុមទំនិញភាគច្រើននៅតែបន្តកើនឡើងបើធៀបនឹងខែវិច្ឆិកា ឆ្នាំ២០១៦ ដូចជាសន្ទស្សន៍ថ្លៃភោជនីយដ្ឋាន, ដឹកជញ្ជូន, សម្លៀកបំពាក់និងស្បែកជើង, អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង, និងភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់។ សន្ទស្សន៍ថ្លៃដឹកជញ្ជូនកើនឡើងក្នុងអត្រា ៤,៣% ក្នុងនោះថ្លៃប្រេងសាំងធម្មតា និងម៉ាស៊ូត នៅតែបន្តកើនឡើងគួរអោយកត់សម្គាល់គឺកើនក្នុងអត្រា ៩,៥% និង៨,៣% រៀងគ្នា ដែលប្រេងសាំងធម្មតាលក់រាយកម្ពុជាថ្លៃ ៣.៨៥០រៀល/លីត្រ (ខែតុលាកន្លងទៅប្រេងសាំងធម្មតាថ្លៃ ៣.៧៥០ រៀល/លីត្រ)។ ស្ថានភាពនៃបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញក្នុងកំឡុងពេលចុងឆ្នាំ ២០១៧នេះ គឺមានកំណើនទាបជាងអំឡុងពេលដូចគ្នាឆ្នាំ២០១៦ ដែលកំណើនទាបនេះគឺ ដោយសារការថមថយកំណើននៃថ្លៃក្រុមទំនិញម្ហូបអាហារ, ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ និងសម្លៀកបំពាក់និងស្បែកជើង។

តាមការធ្វើចំណោលគិតដល់ត្រឹមខែធ្នូ ឆ្នាំ២០១៧ អតិផរណាប្រចាំឆ្នាំ (year on year) អាចនឹងមានអត្រា ១,៩% ឬ អតិផរណាមធ្យមប្រចាំឆ្នាំ (year average) អាចនឹងមានអត្រា ២,៩%។

**តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%)**

| | ធៀបនឹងខែមុន | ធៀបនឹង១ឆ្នាំមុន |
|---|---|---|
| **មុខទំនិញគ្រប់មុខ** | **+0,២** | **+២,៣** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | +0,៤ | +២,0 |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | -0,៨ | +0,៦ |
| ៣- សម្លៀកបំពាក់និងស្បែកជើង | -0,១ | +២,៥ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន | -0,២ | -0,១ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ | 0,0 | +0,២ |
| ៦-សុខាភិបាល | 0,0 | +១,៣ |
| ៧-ការដឹកជញ្ជូន | +0,១ | +៤,៣ |
| ៨-គមនាគមន៍ | 0,0 | -0,៤ |
| ៩-ការកំសាន្ត និងវប្បធម៌ | -0,៤ | -១,១ |
| ១0-ការសិក្សា | 0,0 | -0,៧ |
| ១១-ភោជនីយដ្ឋាន | +0,៣ | +៨,៤ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | +0,៤ | +១,៦ |

| តារាង ១ ÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ (%) | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបខែមុន | | | ធៀបនឹងឆ្នាំមុន | | |
| | ២០១៧ | | | ២០១៧ | | |
| | កញ្ញា | តុលា | វិច្ឆិកា | កញ្ញា | តុលា | វិច្ឆិកា |
| អង្ករ | +0,២ | +0,១ | +0,៣ | +២,0 | +២,២ | +២,0 |
| សាច់គោ | +0,៧ | -0,១ | +0,៤ | +២,៨ | +២,៤ | +២,៥ |
| សាច់មាន់ | -0,១ | +0,៤ | 0,0 | +១,៨ | +១,២ | +១,២ |
| សាច់ទា | -0,៨ | +0,៦ | +0,៣ | -0,១ | +0,៧ | +0,៩ |
| សាច់ជ្រូក | +0,១ | -0,៧ | +0,៤ | +១,0 | +0,៥ | +១,0 |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | +១,៩ | -0,៨ | +១,២ | +៥,៨ | +៤,៣ | +៤,៩ |
| ក្នុងនោះត្រីស្រស់ | +២,២ | -១,១ | +១,៤ | +៦,0 | +៤,១ | +៥,២ |
| ផ្លែឈើ | 0,0 | 0,0 | -0,៣ | +0,៦ | 0,0 | +0,៨ |
| ផ្លែឈើស្រស់ | 0,0 | 0,0 | -0,៤ | 0,0 | -0,៨ | 0,0 |
| បន្លែ | 0,0 | -0,៩ | 0,0 | +២,៩ | -0,១ | -១,៣ |
| បន្លែជាស្លឹក | -0,៦ | -១,៣ | +១,៣ | +៣,៤ | -១,៣ | -១,៧ |
| បន្លែជាផ្លែ | -0,៦ | -0,១ | -១,៥ | -0,៨ | -១,៩ | -៤,៥ |

## ខ/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង៣÷ អតិផរណាប្រចាំឆ្នាំ (គិតជា %) | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេស | ២០១៦ | ២០១៧ | | | | | | | | | |
| | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា |
| ប្រទេសកម្ពុជា | 3.9 | 4.4 | 4.0 | 4.3 | 3.2 | 2.5 | 2.3 | 2.3 | 2.6 | 2.7 | 2.1 | 2.3 |
| ប្រទេសវៀតណាម | 4.74 | 5.2 | 5.0 | 4.7 | 4.3 | 3.2 | 2.5 | 2.5 | 3.4 | 3.4 | 3.0 | 2.6 |
| ប្រទេសថៃ | 1.13 | 1.6 | 1.4 | 0.8 | 0.4 | -0.04 | -0.05 | 0.2 | 0.3 | 0.9 | 0.9 | 0.99 |
| ប្រទេសម៉ាឡេស៊ី | 1.8 | 3.2 | 4.5 | 5.1 | 4.4 | 3.9 | 3.6 | 3.2 | 3.7 | 4.3 | 3.7 | 3.4 |
| ប្រទេសឥណ្ឌូនេស៊ី | 3.02 | 3.5 | 3.8 | 3.6 | 4.2 | 4.3 | 4.4 | 3.9 | 3.8 | 3.7 | 3.6 | 3.3 |
| ប្រទេសហ្វីលីពីន | 2.6 | 2.7 | 3.3 | 3.4 | 3.4 | 3.1 | 2.8 | 2.8 | 3.1 | 3.4 | 3.5 | 3.3 |
| ប្រទេសចិន | 2.1 | 2.5 | 0.8 | 0.9 | 1.2 | 1.5 | 1.5 | 1.4 | 1.8 | 1.6 | 1.9 | 1.7 |
| ប្រទេសកូរ៉េខាងត្បូង | 1.3 | 2.0 | 1.9 | 2.2 | 1.9 | 2.0 | 1.9 | 2.2 | 2.6 | 2.1 | 1.8 | 1.3 |
| ប្រទេសជប៉ុន | 0.3 | 0.4 | 0.3 | 0.2 | 0.4 | 0.4 | 0.4 | 0.4 | 0.7 | 0.7 | 0.2 | 0.6 |

ប្រភពទិន្នន័យ

(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)

(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

## កំណត់សម្គាល់

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

***រៀបចំនិងធ្វើចំណោលដោយ***

***នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច***

***អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***